# របាយការណ៍សង្ខេបលទ្ធផល
# ការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣
# និងទិសដៅការងារឆ្នាំ២០១៤
# អាជ្ញាធរជាតប្រយុទ្ធប្រឆាំងគ្រឿងញៀន

(ដោយ ឯ.ឧ .ឯក មាស ចរិទ្ធ អគ្គលេខាធិការអ.ជ.ប.គ.ញ)

រាជធានីភ្នំពេញ,ថ្ងៃទី ២៥-២៦ ខែ មិនា  ឆ្នាំ២០១៤

# មាតិកា

I. **សភាពការណ៍គ្រឿងញៀន**

១.សភាពការណ៍គ្រឿងញៀនក្នុងតំបន់និងក្នុងសកលលោក

២.សភាពការណ៍គ្រឿងញៀននៅកម្ពុជា

II. **លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន**

១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន

២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

៣.ការងារកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម

៤.ការពង្រឹងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់

៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

III. **ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤**

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# សភាពការណ៍គ្រឿងញៀន

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# ការដាំដុះ និងការផលិតគ្រឿងញៀន

## ការដាំដុះនិងការផលិតគ្រឿងញៀនលើសកលលោកពុំមានសញ្ញាណថយចុះ

- ដំណាំអាភៀននិងការផលិតហេរ៉ូអ៊ីនមានការកើនឡើង។
- ទីតាំងផលិតគ្រឿងញៀនសំយោគATS នៅអាស៊ីខាងកើតនិងអាស៊ី អគ្នេយ៍បានកើនឡើងជាច្រើនកន្លែង។
- ការផលិតគ្រឿងញៀនសំយោគATS បច្ចុប្បន្ន គេបានប្រើប្រាស់សារធាតុគីមីផ្សំ ផ្សេងពីសារធាតុគីមីផ្សំដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ UN និងមិនមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។







# ការចរាចរ ជួញដូរ គ្រឿងញៀន

- បរិមាណនៃការរឹបអូសគ្រឿងញៀនមេតំហ្វេតាមីនខុសច្បាប់កើនឡើងនៅតំបន់អាស៊ីខាងកើត និងអាស៊ីអគ្នេយ៍។
- ឧក្រិដ្ឋជនអាហ្វ្រិកខាងលិច បាននិងកំពុងបង្កើនសកម្មភាពចរាចរដឹកជញ្ជូនគ្រឿងញៀនយ៉ាងសកម្មមកកាន់តំបន់អាស៊ី-ប៉ាស៊ីហ្វិក។
- ការចរាចរគ្រឿងញៀនខុសច្បាប់នៅតាមច្រកសមុទ្រ និងតាមច្រកអាកាសយានដ្ឋានអន្តរជាតិ ក៏មានសកម្មភាពគួរឲ្យកត់សម្គាល់។








# ការចរាចរ ជួញដូរ គ្រឿងញៀន (ត)

- និន្នាការថ្មីនៃការជួញដូរគ្រឿងញៀន,ការជួញដូរសារធាតុ ស្ថិតក្រោមការត្រួតពិនិត្យរួម ទាំងការជួញដូរឱសថដែលមានផ្ទុកសារធាតុត្រួតពិនិត្យ, ឯការទូទាត់ឬបង្វែរសាច់ប្រាក់ គឺធ្វើឡើងតាម ប្រព័ន្ធអ៊ីនធឺណិតនិងប្រព័ន្ធបច្ចេកវិទ្យាឬការ បញ្ជាទិញទំនិញផ្សេងៗ។

- ក្រុមឧក្រិដ្ឋជនគ្រឿងញៀនប្រទេសអៀរ៉ង់ និងចិនត្រូវបានគេចាត់ទុកជាក្រុមឧក្រិដ្ឋជន យ៉ាងសកម្មក្នុងការជួញដូរនិងដឹកជញ្ជូន។

- ផ្លូវចរាចរគ្រឿងញៀនដែលក្រុមឧក្រិដ្ឋជន កំពុងប្រើប្រាស់នៅក្នុងតំបន់អាស៊ី-អគ្នេយ៍គឺ ការដឹកជញ្ជូនពីតំបន់ត្រីកោណមាស ចូលមកតាមខេត្តភាគខាងជើងប្រទេសថៃ និងប្រទេសឡាវ មុននឹងចរាចរទៅកាន់បណ្តាប្រទេសនៅក្នុងមហាអនុតំបន់ ទន្លេមេគង្គនិងទីផ្សារគ្រឿងញៀនអន្តរជាតិ។



# សភាពការណ៍
# គ្រឿងញៀននៅកម្ពុជា

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# ការចរាចរគ្រឿងញៀន

- គ្រឿងញៀននៅតែបន្តចរាចរឆ្លងកាត់ចូលមកកម្ពុជាពីតំបន់ត្រីកោណមាស តាមច្រកនៃបណ្ដាខេត្តជាប់ព្រំដែនឡាវ ជាពិសេសគ្រឿងញៀនសំយោគATS មេតំហ្វេតាមីនគ្រាប់(WY) មេតំហ្វេតាមីនក្រាមម្សៅ (ICE) និងហេរ៉ូអ៊ីន។




- ហេរ៉ូអ៊ីននិងមេតំហ្វេតាមីនក្រាមម្សៅ (ICE) មួយចំនួនត្រូវបាននាំមកពីតំបន់អឌ្ឍចន្ទមាស ចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប។

- កូកាអ៊ីននិងមេតំហ្វេតាមីនក្រាមម្សៅ (ICE) ត្រូវបាននាំមកពីតំបន់អាមេរិកឡាទីន។

*រួមគ្នាធ្វើសកម្មភាពដើម្បីស*



គ្រឿងញៀនប្រភេទហេរ៉ូអ៊ីន (Heroin) ទម្ងន់ ៦.០៣៥គីឡូក្រាម



គ្រឿងញៀនប្រភេទកូកាអ៊ីន(Cocaine) ទម្ងន់សរុប ២,៩១៦.០៧ក្រាម

# ការកែច្នៃផលិតគ្រឿងញៀនសំយោគ ATS
# ការដាំដុះ និងការចម្រាញ់ប្រេងរុក្ខជាតិ

- គ្រឿងញៀនសំយោគATS នៅតែបន្តសកម្មភាពលួចផលិតកែច្នៃដោយខុសច្បាប់ ជាក់ស្តែងសមត្ថកិច្ចយើងបានបង្ក្រាបករណីលួចផលិតនៅសង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក។
- ដំណាំកញ្ឆាត្រូវបានកាត់បន្ថយនិងលុបបំបាត់ស្ទើរតែទាំងស្រុង។
- ការចម្រាញ់ប្រេងម្រះព្រៅភ្នំក៏ស្ថិតនៅក្នុងបរិមាណមួយទាបបំផុត។



# ការប្រើបំពានគ្រឿងញៀន

- ការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា មានចំនួន ១៣,០០០នាក់ (ចំនួននេះប្រែប្រួលក្នុងចន្លោះ១២,០០០ ទៅ ២៨,០០០នាក់) អាយុភាគច្រើនក្រោម៣៥ឆ្នាំ។

- អ្នករងគ្រោះធ្ងន់ធ្ងរស្នាក់នៅក្នុងមណ្ឌលបណ្ដោះអាសន្នមាន២,៧១៣ នាក់៖
  - ភាគច្រើនប្រើថ្នាំញៀនប្រភេទមេតំហ្វេតាមីនក្រាមម្សៅ (ICE)
  - ភាគច្រើនមានអាយុ ចន្លោះពី ១៨ ទៅ ៣៥ ឆ្នាំ
  - ភាគច្រើនគ្មានមុខរបរពិតប្រាកដ
- ការប្រើគ្រឿងញៀនដោយការចាក់ក៏នៅបន្តកើតមាន។







# លទ្ធផលការងារ
# ប្រយុទ្ធប្រឆាំងគ្រឿងញៀន

រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន

# ការកាត់បន្ថយតម្រូវការគ្រឿងញៀន











ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅខេត្តបន្ទាយមានជ័យ

សកម្មភាពប្រគំតន្ត្រីប្រឆាំងគ្រឿងញៀន






*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# ចំណុចខ្វះខាត និងបញ្ហាប្រឈម

- កង្វះខាតធនធានមនុស្ស សម្ភារៈបច្ចេកទេស និង ថវិកា សម្រាប់ដំណើរការកម្មវិធីផ្សព្វផ្សាយអប់រំ។
- គោលដៅកើតឡើងនូវបញ្ហាគ្រឿងញៀន ដែលធ្លាប់បានចាត់វិធានការអប់រំ បង្ការទប់ស្កាត់ នៅតែមានបញ្ហាគ្រឿងញៀនកើតឡើង។
- ចលនាគំរូ បុគ្គលល្អ គ្រួសារល្អ ដែលបានចាកចេញពីគ្រឿងញៀន និងការប្រលងប្រណាំងលើវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមទាំងការសរសើរលើកទឹកចិត្តចំពោះអ្នកមានស្នាដៃនៅមិនទាន់ធ្វើបានល្អ។

# ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន




ជនសង្ស័យមាន១៦សញ្ជាតិៈ ខ្មែរ វៀតណាម ឡាវ ថៃ ហ្វីលីពីន ចិន នីហ្សេរីយ៉ា កូរ៉េ អៀរឡង់ ប៉េរូ ឥណ្ឌា ឥណ្ឌូណេស៊ី រ៉ូមានី អេស្ប៉ាញ បារាំង និងអូស្ត្រាលី។

វត្ថុតាងគ្រឿងញៀនសរុប ចំនួន១០២គីឡូក្រាមៈ មេតំហ្វេតាមីនគ្រាប់( WY),មេតំហ្វេតាមីនក្រាមម្សៅ(ICE),ហេរ៉ូអ៊ីន, កូកាអ៊ីន, កេតាមីននិងកញ្ឆា។

# ចំណុចខ្វះខាត និងបញ្ហាប្រឈម

- ការយល់ដឹងទូទៅអំពីច្បាប់គ្រឿងញៀនរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិត។
- ប្រភពព័ត៌មានពហុវិស័យសម្រាប់បម្រើឱ្យកិច្ចសហប្រតិបត្តិការនៅមិនទាន់មានគ្រប់គ្រាន់។
- ការិយាល័យទំនាក់ទំនងព្រំដែន(BLO) ដែលបានបង្កើតឡើងរួចហើយសម្រាប់ត្រួតពិនិត្យលើបញ្ហាគ្រឿងញៀននៅ តាមខ្សែបន្ទាត់ នៅមិនទាន់បំពេញតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានទូលំទូលាយនិងជាប់ជាប្រចាំ។
- បណ្តាខេត្តភាគល្អសាននៅតែត្រូវបានចាត់ទុកជាខេត្តដែលមានលំហូរចូលគ្រឿងញៀនខុសច្បាប់។

# ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្ដារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

- បានបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធការងារកាត់បន្ថយគ្រោះថ្នាក់ទាំងក្នុងនិងក្រៅប្រទេស ចំនួន១,៨១៧នាក់។
- បានពង្រឹងសមត្ថភាពដល់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ១៨៥ កន្លែង។
- បានបណ្តុះបណ្តាលមន្ត្រីមន្ទីរសុខាភិបាលខេត្ត, គ្រូពេទ្យព្យាបាល, គិលានុបដ្ឋាក-គិលានុបដ្ឋាយិកា និងមន្ត្រីសុខាភិបាល ពន្ធនាគារ ចំនួន៤៣០នាក់ នៅតាមគោលដៅ និងក្រៅប្រទេសចំនួន៤៣នាក់។






# ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម (ត)

- បានព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព អ្នកញៀន ATS ថ្មី ចំនួន ៣៥៩នាក់(ចាស់៤៨៩នាក់), អ្នកញៀនអាភៀនថ្មី ចំនួន៥៦នាក់(ចាស់១៣១នាក់)។

- បានទទួលអ្នកញៀនគ្រឿងញៀនមកព្យាបាលក្នុងមណ្ឌលបណ្តោះអាសន្ន ចំនួន ២,៧១៣នាក់៖
  - បានធ្វើ សមាហរណកម្មទៅសហគមន៍វិញចំនួន១,៤៤៦នាក់,
  - បោះបង់ចោលការព្យាបាលចំនួន ២នាក់,
  - នៅសល់ជាក់ស្តែងកំពុងព្យាបាលបន្តចំនួន ១,២៦៥នាក់។







# ចំណុចខ្វះខាត និងបញ្ហាប្រឈម

- មាតាបិតាអាណាព្យាបាលដែលមានកូនចៅញៀនគ្រឿងញៀន ភាគច្រើនមិនហ៊ានរាយការណ៍ជូនសមត្ថកិច្ចដើម្បីសមត្ថកិច្ចជួយមានវិធានការនិងមិនទាន់បានដឹងថានៅក្នុងមន្ទីរពេទ្យបង្អែកឬមណ្ឌលសុខភាពក្នុងសហគមន៍របស់ខ្លួនមានកម្មវិធីផ្តល់សេវាព្យាបាល អ្នកញៀនគ្រឿងញៀននៅឡើយ ។




- ការបណ្តុះបណ្តាលជំនាញសម្រាប់ព្យាបាល តាមសហគមន៍មានដំណើរការយឺតយ៉ាវ ដោយសារកង្វះខាតធនធានមនុស្ស សម្ភារៈ បទពិសោធន៍ ជាពិសេសបញ្ហាថវិកា ។

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# ចំណុចខ្វះខាត និងបញ្ហាប្រឈម(ត)

- សេវាព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមមន្ទីរពេទ្យបង្អែកនិង មណ្ឌលសុខភាពមិនទាន់ត្រូវបានពង្រីក និងធ្វើការផ្តល់សេវាឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅឡើយ។

- ប្រព័ន្ធតាមដានត្រួតពិនិត្យលើការចាកចេញនិងការវិលត្រឡប់មកវិញ  នៅមិនទាន់ច្បាស់លាស់។

- មន្ត្រីសុខាភិបាលតាមប៉ុស្តិ៍សុខភាពពន្ធនាគារបានទទួលការបណ្តុះបណ្តាលតែមិនទាន់បានផ្តល់សេវាដល់អ្នកជាប់ពន្ធនាគារនៅឡើយ។

# ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ចំណេះដឹងមូលដ្ឋានអំពីគ្រឿងញៀន, ការស៊ើបអង្កេត បទល្មើសគ្រឿងញៀន បាន ចំនួន ៣,៤១១នាក់។
- អនុម័តលើសេចក្តីសម្រេច ស្តីពី ការកែសម្រួលសមាសភាពតួនាទី និងភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO)។




វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់
ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន,ថៃឡង់ដ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ : ០០១/ស.ស.ឥ.អ.ជ.ប.គ.ញ
១៣

សេចក្តីសម្រេច

ស្តីពី

ការកែសម្រួល សមាសភាព តួនាទី និងភារកិច្ច
ការិយាល័យទំនាក់ទំនងព្រំដែន
Border Liaison Office ( BLO )

# ចំណុចខ្វះខាត និងបញ្ហាប្រឈម

➤និតិវិធីក្នុងការស៊ើបអង្កេត ប្រមូលភស្តុតាងគ្រឿងញៀនសម្រាប់ផ្តល់ជូនស្ថាប័ន តុលាការ ដោយមន្ត្រីអនុវត្តច្បាប់មួយចំនួននៅមានកម្រិត។

➤ការគោរពស្មារតី និងខ្លឹមសារច្បាប់គ្រឿងញៀន ពុំទាន់អនុវត្តបានល្អនៅឡើយ  ដោយមន្ត្រីមួយចំនួនឆ្លៀតឱកាសយកវិជ្ជាជីវៈធ្វើជាមុខរបរ បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន។

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# កិច្ចសហប្រតិបត្តិការអន្តរជាតិ

- យើងបានខិតខំបន្តពង្រឹងនិងពង្រីក កិច្ចសហប្រតិបត្តិការតាមរយៈយន្តការ ទ្វេភាគី ត្រីភាគី និងពហុភាគី ជាមួយប្រទេសទាំងក្នុងនិងក្រៅតំបន់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ការងារត្រួតពិនិត្យគ្រឿងញៀនតាមរយៈកិច្ចសហប្រតិបត្តិការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន ការចូលរួមនិងទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានាសរុប ចំនួន៤៥លើក។



ប្រជុំទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម- ឡាវ, ខេត្តសៀមរាប



# ចំណុចខ្វះខាត និងបញ្ហាប្រឈម

- គម្រោងទាំងឡាយដែលផ្តល់ដោយដៃគូអន្តរជាតិនានា លើវិស័យត្រួតពិនិត្យគ្រឿងញៀន ទាំងដៃគូទ្វេភាគី អនុតំបន់ តំបន់ និងអន្តរជាតិ នៅតែស្ថិតក្នុងស្ថានភាពបោះជំហានយឺតៗ។

*រួមគ្នាធ្វើសកម្មភាពដើម្បីសហគមន៍យើងគ្មានគ្រឿងញៀន*

# ទិសដៅការងារ ត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤

១.ជំរុញការផ្សព្វផ្សាយអប់រំ តាមគ្រប់រូបភាពជាប្រចាំនិងចំគោលដៅ ប្រឈមនានា និងចលនាឲ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានសំដៅកាត់បន្ថយតម្រូវការគ្រឿងញៀន។

២. ពង្រីកកម្មវិធីព្យាបាល អ្នកញៀនគ្រឿងញៀនផ្អែកលើសហគមន៍ដោយប្រើប្រាស់ប្រព័ន្ធសុខាភិបាល និងប្រព័ន្ធសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាដែលមានស្រាប់។ ពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្ន, ជំរុញការរៀបចំបង្កើតមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនថ្នាក់ជាតិ,

៣.ចាត់វិធានការគ្រប់បែបយ៉ាង តាមផ្លូវច្បាប់និងរដ្ឋបាល ដើម្បីប្រឆាំងការផលិត, ការដាំដុះ, ការចម្រាញ់, ការចរាចរជួញដូរ, ការស្តុកទុកនិងប្រើប្រាស់គ្រឿងញៀន ចាប់ពីរូបភាពតូចតាចរហូតដល់រូបភាពធំៗ។

៤. បង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំ ដែលនាំចូលស្របច្បាប់ និងមិនស្របច្បាប់ព្រមទាំងវត្ថុធាតុដើម ឬសារធាតុផ្សំមួយចំនួនទៀត ដើម្បីបង្ការការបង្វែរ និងទប់ស្កាត់សារធាតុទាំងនោះកុំឱ្យ យកមកសំយោគផលិតទៅជាគ្រឿងញៀនខុសច្បាប់ ។

៥. ជំរុញនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសជិតខាងតាមគ្រប់រូបភាព និងបន្តពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន (BLOs) ។

៦.ជំរុញនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេសនានាក្នុងតំបន់ និងសកលលោកព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ តាមគ្រប់រូបភាពដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន ។

៧.ពង្រឹងស្ថាប័នសេនាធិការ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ,អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកលទ្ធភាពអនុវត្តយុទ្ធសាស្រ្តរបស់អាជ្ញាធរជាតិឱ្យមានប្រសិទ្ធភាព។

# ផែនការសកម្មភាព
# អនុវត្តទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៤

## ដូចមានក្នុងរបាយការណ៍ពិស្តារ

# សូមគោរពថ្លែងអំណរគុណ

## រៀបចំដោយ អនុគណៈកម្មការ ឯកសារ

## ព័ត៌មានពិស្តារសូមអញ្ជើញទស្សនា

## គេហទំព័រ www.nacd.gov.kh